សមិទ្ធផលវិស័យធនធានទឹក និងឧតុនិយម ចុងអាណត្តិទី ២ និងដើមអាណត្តិទី ៣ នៃរដ្ឋសភា

(ភាគ ៣)













ប្រសាសន៍សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា នៅក្នុងពិធីសម្ពោធជាផ្លូវការអាងទឹកតាមោក ស្រុកពញ្ញាឮ ខេត្តកណ្តាលនាថ្ងៃទី ៨ ខែ មករា ឆ្នាំ ២០០៥

"ឥឡូវគិតចែកអាណាត្តិនេះ ឯកឧត្តម គាត ឈន់ សម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ និងខ្ញុំ ឯកភាពគ្នាថា ប្រកាសថា៖ រដ្ឋាភិបាលអាណត្តិនេះ គឺរដ្ឋាភិបាលធារាសាស្ត្រ រដ្ឋាភិបាលអាណត្តិទីពីរ គឺរដ្ឋាភិបាលផ្លូវថ្លង ៗ រដ្ឋាភិបាលអាណត្តិនេះ គឺរដ្ឋាភិបាលធារាសាស្ត្រ អញ្ចឹងទេ ខ្ញុំប្រាប់ឯកឧត្តម លឹម គានហោ ហើយថា លើកគំរោងមកគំរោងដែលជាជំនួយអន្តរជាតិ អាហ្នឹង យើងអភិវឌ្ឍន៍តាមជំនួយអន្តរជាតិ ឬកម្ចី ប៉ុន្តែគំរោងណា ដែលខ្ញុំចង្អុល ដូចជាឈ្វាំង ឥឡូវគ្រឿងចក្រចុះដល់ កន្លែងណាទៀតដែលខ្ញុំចង្អុល ជាក់ទៅលើ ប៉ុន្មានឆ្នាំចុងក្រោយគឺថា យើងដោះស្រាយបាន បើយើងមិនចាប់ផ្តើមដំណើរការពី ពីទឹកទេ យើងមិនអាចធ្វើអោយសេដ្ឋកិច្ចរបស់យើងស្ទុះរួចទេ ឆ្នាំណា ក៏ឆ្នាំខ្វះទឹក ឆ្នាំណា ក៏ប៉ះជំនន់ ឆ្នាំណាក៏ ខាមានកន្លែងនេះ កន្លែងនោះ ៗ"

លិខិតថ្វាយព្រះពរ និងជូនពរ

ទូលព្រះបង្គំ យើងខ្ញុំ

ជាមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ នៃ

ក្រសួងធនធានទឹក និងឧតុនិយម

ម.ព.ឯ.ក AIDOC
Code: 157-006
Date:
Donated by:

សូម

ក្រាបបង្គំទូលថ្វាយ ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរៈក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯករាជ្យជាតិខ្មែរ និងសម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសើរភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល

ក្រាបបង្គំទូលថ្វាយ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជណាចក្រកម្ពុជា ជាទីគោរពសក្តារៈដ៏ខ្ពង់ខ្ពស់ នូវ មនោសញ្ចេតនា ប្រកបជោយកតញ្ញូកតវេទិតាធម៌យ៉ាងស្មោះស្មំត្របំផុត និងសូមព្រះរាជានុញ្ញាតថ្វាយនូវព្រះរាជសព្ទសាធុការពរជ៏យ បវរសួស្តី សីរីមង្គល វិបុលសុខ ព្រះរាជសុខភាពមាំមួន ព្រះជន្មាយុយឺនយូរ ជាងរយព្រះវស្សា

សូមថ្វាយព្រះពរ និងជូនពរ

សម្តេច ព្រះអង្គម្ចាស់ ព្រះអង្គម្ចាស់ក្សត្រីយ៍ លោកជំទាវ ឯកឧត្តម អ្នកឧកញ៉ា លោក លោកស្រី សូមជូបតែនឹងពុទ្ធពរទាំងប្រាំប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈកុំបីឃ្លៀងឃ្លាតឡើយ

ឯកឧត្តម **លីម ភានហោ**

រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម

ព្រមទាំងមន្ត្រីរាជការទាំងអស់ក្រោមឱ្យវាទ

អារម្ភកថា

ក្នុងរយៈពេល២អាណត្តិកន្លងមកនេះ រាជរដ្ឋាភិបាលបានដាក់ទិសដៅពីសំខាន់ៗគឺការកាត់បន្ថយភាពក្រីក្រ និងយុទ្ធសាស្ត្រចតុកោណដល់ក្រសួង និងស្ថាប័ននានាអនុវត្តន៍ដើម្បីធានាសុវត្ថិភាពស្បៀងដល់ប្រជាជនកម្ពុជា ។ ជាក់ស្តែងថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងធនធានទឹក និងឧតុនិយម បានខិតខំយកអស់កំលាំងកាយចិត្ត ក្នុងការបំពេញភារកិច្ចដោយទទួលបានសមិទ្ធផលល្អគួរជាទីមោទនៈ ។ ស្បៀវភៅដែលបង្ហាញនូវសមិទ្ធផលវិស័យធនធានទឹក និងឧតុនិយមចុងអាណត្តិទី ២ និងដើមអាណត្តិទី ៣ នៃរដ្ឋសភា ភាគ៣ បានប្រមូលនូវប្រព័ន្ធសំណង់តូច ធំ សំខាន់ៗរបស់ក្រសួងក្នុងពេលកន្លងមកក្រោមការដឹកនាំដ៏ឈ្លាសវៃ និងមានសម្ថភាពខ្ពស់របស់ឯកឧត្តម **ឈឹម គានហោ** ដែលជានិច្ចជាកាលតែងតែយកចិត្តទុកដាក់លើបញ្ហាទឹកដែលជាកត្តាលើករដ៏សំខាន់សំរាប់អភិវឌ្ឍន៍លើគ្រប់វិស័យ ពិសេសជំរុញវិស័យកសិកម្មនៅប្រទេសកម្ពុជា អោយមានការរីកចំរើនថែមទៀត ស្របតាមពាក្យថា ទឹកជាមាស (ស) ។ នេះបង្ហាញអោយឃើញយ៉ាងប្រត្យក្សថា ក្រសួងធនធានទឹក និងឧតុនិយម បានឆ្លើយតបទៅនឹងភារកិច្ចដ៏ឧត្តុងឧត្តម ដែលសម្តេច **ហ៊ុន សែន** ប្រមុខរាជរដ្ឋាភិបាលកម្ពុជា បានប្រគល់ជូន ។

ទន្ទឹមនឹងនេះក្រសួងធនធានទឹក និងឧតុនិយម សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងកក់ក្តៅជាទីបំផុតចំពោះស្ថាប័នជាតិ និងអន្តរជាតិនានា ដែលបានជួយឧបត្ថម្ភគាំទ្រ និងមានកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរ ធ្វើអោយសំរេចបាននូវសមិទ្ធិផលដ៏ត្រចះត្រចង់គួរជាទីមោទនៈនេះឡើង ។

ពិធីចុះហត្ថលេខា ស្តីពីការទទួលជំនួយឥតសំណងពីរាជរដ្ឋាភិបាលជប៉ុន



នាថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៥ សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា បានចូលរួមជាអធិបតីភាពក្នុងពិធីចុះហត្ថលេខា ស្តីពីការផ្តល់ជំនួយ ឥតសំណងរបស់រាជរដ្ឋាភិបាលជប៉ុនជិត ៤០ លានដុល្លារសហរដ្ឋអាមេរិក ដល់រាជរដ្ឋាភិបាលកម្ពុជា

ពិធីប្រគល់-ទទួលអ៊ុចស្ការ៉ាំងចំនួន ២០ គ្រឿង ដែលជាជំនួយឥតសំណងរបស់សាធារណរដ្ឋប្រជាមានិតចិន







ឯកឧត្តមរដ្ឋមន្ត្រី **លឹម គានហោ** និងឯកឧត្តមឯកអគ្គរដ្ឋទូតចិន ថ្លែងសុន្ទរថាក្នុងឱកាសពីធីប្រគល់-ទទួលអ៊ុចស្ការ៉ាំងចំនួន ២០ គ្រឿង

ឯកឧត្តម **លឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងឯកឧត្តមឯកអគ្គរដ្ឋទូតចិន ចុះហត្ថលេខាលើពិធីសារ ស្តីពីការប្រគល់-ទទួលអ៊ុចស្ការ៉ាំងចំនួន ២០ គ្រឿង





ឯកឧត្តម **លឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ទទួលសោតំណាងអ៊ុចស្ការ៉ាទ័រ ចំនួន ២០ គ្រឿង ពីឯកឧត្តមឯកអគ្គរដ្ឋទូតចិន



ឯកឧត្តមរដ្ឋមន្ត្រី **លឹម គានហោ** និងឯកឧត្តមឯកអគ្គ-រដ្ឋទូតចិន អញ្ជើញទស្សនាអ៊ុចស្ការ៉ាទ័រ ចំនួន ២០ គ្រឿង ដែលជាជំនួយឥតសំណងរបស់សាធារណរដ្ឋប្រជាមានិតចិន



អ៊ុចស្ការ៉ាទ័រចំនួន ២០ គ្រឿង ដែលជាជំនួយឥតសំណងរបស់សាធារណរដ្ឋប្រជាមានិតចិន

ពិធីសម្ពោធជាផ្លូវការ អាងទឹកតាមោក



*សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា បានអញ្ជើញចូលរួមក្នុងពិធីសម្ពោធ ជាផ្លូវការ អាងទឹកតាមោក ស្រុកពញាឮ ខេត្តកណ្តាល*

អាងទឹក **តាមោក** ស្ថិតនៅក្នុង ស្រុកពញាឮ ខេត្តកណ្តាល មានចំងាយប្រមាណ ១២ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ តាមបណ្តោយផ្លូវជាតិលេខ ៥ ។ ជារៀងរាល់ឆ្នាំក្នុងរដូវវស្សាក្នុងអំឡុងពេលដែលមានទឹកជំនន់ទន្លេមេគង្គឡើងខ្លាំង ធារទឹកមួយផ្នែកធំបានហូរចាក់ចូលក្នុងបឹងទន្លេសាប. ចូលទៅសមុទ្រចិនភាគខាងត្បូងតាមរយៈទន្លេបាសាក់ និងទន្លេមេគង្គក្រោម ហើយមួយផ្នែកទៀតបានហូរទៅកាន់តំបន់ទំនាប បឹងបួរនានា ដែលនៅជុំវិញបឹងទន្លេសាប ។ ក្នុងពេលជាមួយគ្នានេះអាងទឹក **តាមោក** ដែលស្ថិតក្នុងផ្នែងទឹកជំនន់បឹងទន្លេសាប ក៏បានទទួលនូវការហូរចាក់បំពេញពីទឹកជំនន់នេះផងដែរ ។ ដោយសារតែឥទ្ធិពលពីទឹកជំនន់នេះហើយទើបនៅឆ្នាំ ១៩៨០ អតីតរដ្ឋកម្ពុជាបានប្រែក្លាយអាងទឹក **តាមោក** នេះទៅជាហេដ្ឋារចនាសម្ព័ន្ធ ធារាសាស្ត្រសំរាប់ស្តុកទឹកក្នុងរដូវទឹកជំនន់ ដើម្បីបំរើដល់ការស្រោចស្រពស្រូវរដូវប្រាំង ជូនប្រជាកសិករ បានប្រមាណ១៩០០ ហិកតា ដែលស្ថិតនៅជុំវិញអាង ។ ប៉ុន្តែដោយថវិកាជាតិនៅពេលនោះ នៅមានកំរិត និងមានទឹកជំនន់ធំៗជាប់ៗគ្នាក្នុងប៉ុន្មានឆ្នាំ កន្លងមកនេះ បានធ្វើអោយហេដ្ឋារចនាសម្ព័ន្ធអាងទាំងមូលរងនូវការខូចខាតជាច្រើន។ ដោយស្របតាមយុទ្ធសាស្ត្រ របស់រាជរដ្ឋាភិបាល លើការស្តារ និងការកសាង ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ ស្ថិតនៅក្នុងមុំទី ២ នៃយុទ្ធសាស្ត្រចតុកោណ របស់រាជ

រដ្ឋាភិបាល ដែលមានសម្តេច **ហ៊ុន សែន** ជាប្រមុខ អាងទឹក **តាមោក** ត្រូវបានស្តារ និងជួសជុលឡើងវិញ បន្ទាប់ពីការចុះហត្ថលេខាលើពិធីប្តូរសារ ស្តីពីការផ្តល់ជំនួយ ឥតសំណងនូវទឹកប្រាក់ចំនួន ១.៣៦៥.000 USD រវាង ក្រសួងធនធានទឹក និងឧតុនិយម និងសាជីវកម្មធនធានទឹក កូរ៉េ **(KOWACO)** នាថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២00២ នាទីក្រុង Daejeon សាធារណរដ្ឋកូរ៉េ និងមួយផ្នែក ទៀតជាថវិកា បដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា មានចំនួន ៦៤.៥៥២.២៦ USD ទើបបានស្តារ និង ជួសជុលបញ្ចប់ជាស្ថាពរ កាលពីថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២00៤ ព្រមទាំងបានសម្ពោធដាក់អោយ ប្រើប្រាស់ជាផ្លូវការនាថ្ងៃទី ៨ ខែមករា ឆ្នាំ ២00៥ ក្រោម អធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃ រាជរដ្ឋាភិបាលកម្ពុជា ។ ក្រោយពេលស្តារ និងជួសជុលរួច អាងទឹក **តាមោក** មានអត្ថប្រយោជន៏ ធំៗចំនួន ៤ គឺ :

- ស្តារឡើងវិញនូវអាងទឹក ដោយមានភ្ជាប់ប្រព័ន្ធ ស្រោចស្រពរួចជាស្រេច
- បង្កើន និងធ្វើអោយមានស្ថេរភាពផលិតផល កសិកម្ម ក្នុងស្រុកពញាឮ



*សម្តេច **ហ៊ុន សែន** ថ្លែងសុន្ទរកថា*
និងមានមតិសំណេះសំណាលជាមួយប្រជាពលរដ្ឋ

- ផ្តត់ផ្គង់ទឹកស្អាតដល់ទីប្រជុំជនថ្មីដែល កំពុងរៀបចំនៅប៉ែកខាងជើងរាជធានីភ្នំពេញ ។

ក្រៅពីអត្ថប្រយោជន៏ខាងលើ គំរោងនេះ ក៏បានផ្តល់ទឹកសំរាប់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ ប្រជាពលរដ្ឋក្នុងស្រុកពញាឮប្រមាណជា ៣៥00 គ្រួសារ និងគ្របដណ្តប់លើផ្ទៃដីស្រូវរដូវប្រាំង ប្រមាណ ១៩00 ហិកតា ។



*ឯកឧត្តម **លឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម*
ឡើងថ្លែងសេចក្តីរាយការណ៍ការងារស្តារឡើងវិញអាងទឹកតាមោក



ទិដ្ឋភាពប្រជាកសិករចូលរួមក្នុងពិធីសម្ពោធ



ទិដ្ឋភាពសំណង់ទ្វារទឹកមេ តាមោក (ផ្នែកឆ្ពោះ) មុនពេលស្តារ និងជួសជុល



សកម្មភាពកំពុងស្តារ និងជួសជុលសំណង់ទ្វារទឹកមេ តាមោក (ផ្នែកឆ្ពោះ)



សំណង់ទ្វារទឹកមេ តាមោក (ផ្នែកឆ្ពោះ) ក្រោយពេលស្តារ និងជួសជុលរួច

សំណង់ទ្វារទឹករង តាមោក មុនពេលជួសជុល





សំណង់ទ្វារទឹករង តាមោក ក្រោយពេលជួសជុលរួច

ស្ពានបាឡេត៍ចំនួន ១០ កន្លែង ជាក់បំពាក់នៅតំបន់អភិវឌ្ឍន៍ចំរុះខាងលិចរាជធានីភ្នំពេញ









សកម្មភាពបំពាក់ស្ពានបាឡេតំ លើប្រព័ន្ធប្រឡាយ

នៅតំបន់អភិវឌ្ឍន៍ចំរុះខាងលិចរាជធានីភ្នំពេញ



សកម្មភាពថ្នាក់ដឹកនាំ និងមន្ត្រីជំនាញក្រសួង
ធនធានទឹក និងឧតុនិយម ចុះពិនិត្យស្ពាន
បាឡៃតំ ក្រោយពេលបំពាក់រួច នៅតំបន់
អភិវឌ្ឍន៍ចំរុះ ខាងលិចរាជធានីភ្នំពេញ







ការចាវជួសជុលទំនប់កប់ស្រូវ

ទិដ្ឋភាពទំនប់កប់ស្រូវ ដែលទទួលរងនូវការខូចខាត







សកម្មភាពកំពុងជួសជុល ទំនប់កប់ស្រូវ



ថ្នាក់ជីកនាំ
ក្រសួងធនធាន
ទឹក និង
ឧតុនិយម
ចុះពិនិត្យទំនប់
កប់ស្រូវ
ក្រោយពេល
ជួសជុលរួច



ទំនប់កប់ស្រូវ ក្រោយពេលជួសជុលរួច



ការងារជួសជុល និងស្តារប្រព័ន្ធធារាសាស្ត្រស្ទឹងព្រែកឆ្នោត ស្ថិតនៅព្រំប្រទល់រាជធានីភ្នំពេញ និងខេត្តកណ្តាល



ស្ថានភាពប្រឡាយដោះទឹកព្រែកឆ្នោត (ព្រែកកំពឹស) មុនពេលជួសជុល





សកម្មភាពគ្រឿងចក្រកំពុងជួសជុលប្រឡាយដោះទឹកព្រែកឆ្នោត (ព្រែកកំពឹស)

ទិដ្ឋភាពប្រឡាយដោះទឹក ព្រែកឆ្នោត (ព្រែកកំពឹស) ក្រោយពេលជួសជុល







សកម្មភាពគ្រឿងចក្រកំពុងជួសជុល
ទំនប់សណ្តូ ស្ទឹងព្រែកឆ្នោត



ទំនប់សណ្តូ ស្ទឹងព្រែកឆ្នោត ក្រោយពេលជួសជុល



ការងារស្តារប្រព័ន្ធប្រឡាយ នៅក្នុងខេត្តកណ្តាល

ស្ថានភាពប្រឡាយលេខ ១៨ មុនពេលស្តារ
ស្ថិតក្នុងឃុំសំពៅលូន ស្រុកកោះធំ ខេត្តកណ្តាល





សកម្មភាពកំពុងស្តារប្រឡាយលេខ ១៨ ស្ថិត
ក្នុង ឃុំសំពៅលូន ស្រុកកោះធំ ខេត្តកណ្តាល



ស្ថានភាពប្រឡាយលេខ ១៨ ក្រោយពេលស្តាររួច



សកម្មភាពគ្រឿងចក្រកំពុងស្តារប្រឡាយជើមពោធិ៍ ស្ថិតក្នុងឃុំព្រែកទន្លាក់ ស្រុកលើកដែក ខេត្តកណ្តាល



ស្ថានភាពប្រឡាយជើមពោធិ៍ ស្ថិតក្នុងឃុំព្រែកទន្លាក់ ស្រុកលើកដែក ខេត្តកណ្តាល ក្រោយពេលស្តាររួច

សកម្មភាពស្តារប្រឡាយមេរលាំងជ្រៃខាងត្បូង ដែលមានប្រវែង ២៥.០២០ ម៉ែត្រ និង ទន្លឹងបានប្រឡាយប្រវែង ៤ ម៉ែត្រ និងការសាងសង់សំណង់ស្តាក់ទឹក ដើម្បីជួយដល់ការបង្កបង្កើនផលកសិករ នៅស្រុកសំរោងទង និងស្រុកគងពិសី ខេត្តកំពង់ស្ពឺ



សកម្មភាពចាក់ដីបំពេញផ្លូវលំអមប្រឡាយមេរលាំងជ្រៃខាងត្បូងដែលមានបណ្តោយប្រវែង ២៥០២០ម និងទទឹងខ្នងផ្លូវ ៧ម ក្រាលក្រួសក្រហម ក្នុងស្រុកសំរោងទង និងស្រុកគងពីសី ខេត្តកំពង់ស្ពឺ



សកម្មភាពកិនបង្ហាប់ និងស្រោចទឹកផ្លូវលំអមប្រឡាយមេរលាំងជ្រៃខាង ត្បូង



សកម្មភាពរៀបចំគ្រឹះសំណង់ស្តាក់ទឹកប្រឡាយមេរលាំងជ្រៃខាងត្បូង ឃុំរកាកោះ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ







សំណង់ស្ពានឆ្លងកាត់ប្រឡាយរលាំងជ្រៃ



សកម្មភាពកំពុងសាងសង់សំណង់ស្ពាក់ទឹក នៅប្រឡាយមេរលាំងជ្រៃខាងត្បូង



សំណង់ស្ទាក់ទឹកប្រឡាយមេរលាំងជ្រៃខាងត្បូង ក្រោយពេលសាងសង់រួច

សកម្មភាពគ្រឿងចក្រកំពុងស្តារ
ប្រឡាយមេរលាំជ្រៃខាងត្បូង





ឯកឧត្តមរដ្ឋមន្ត្រីចុះពិនិត្យការងារស្តារ
និងពង្រីកប្រឡាយមេរលាំងជ្រៃខាងត្បូង
ព្រមទាំងបានណែនាំពីយុទ្ធសាស្ត្រ
មួយចំនួនដល់ មន្ត្រីជំនាញកងវិស្វកម្ម
ក្រសួងធនធានទឹក និងឧតុនិយម



ប្រឡាយមេរលាំងជ្រៃក្រោយពេលស្តារ និងពង្រីក រួចជាស្ថាពរ ដែលអាចស្រោចស្រពលើផ្ទៃដីបានប្រមាណ
៨៥០០ ហិកតា

សំណង់ស្ពាក់ទឹក បំពាក់លើប្រឡាយមេរលាំងជ្រៃខាងត្បូង ស្ថិតក្នុងស្រុកគងពិសី ខេត្តកំពង់ស្ពឺ









ទិដ្ឋភាពសំណង់ស្ពាក់ទឹក លើប្រឡាយមេ រលាំងជ្រៃ ខាងត្បូង ស្ថិតក្នុងស្រុកគងពិសី ខេត្តកំពង់ស្ពឺ





សកម្មភាពមន្ត្រីជំនាញក្រសួងធនធានទឹក និងឧតុនិយម

ចុះពិនិត្យសំណង់ស្ទាក់ទឹក លើប្រឡាយមេរលាំងជ្រៃខាងត្បូង

ស្ថិតក្នុងស្រុកគងពិសី ខេត្តកំពង់ស្ពឺ









សំណង់ស្នាក់ទឹកលើប្រឡាយមេ
រលាំងជ្រៃ កំពុងជួសជុល



ទិដ្ឋភាពក្រោយសំណង់ស្នាក់ទឹក
លើប្រឡាយមេរលាំងជ្រៃ

ការស្តារប្រឡាយមេ និងសាងសង់សំណង់ស្តាក់ទឹកលើប្រព័ន្ធប្រឡាយ ស្រោចស្រពក្រាំងដីវ៉ាយ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ

ប្រព័ន្ធប្រឡាយក្រាំងដីវ៉ាយ ស្ថិតនៅក្នុងឃុំក្រាំងដីវ៉ាយ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ មានចំងាយប្រមាណ ១៣៣ គ.ម ប៉ែកខាងលិចរាជធានីភ្នំពេញ ។

ប្រព័ន្ធស្រោចស្រពក្រាំងដីវ៉ាយកសាងនៅក្នុងជំនាន់ប៉ុលពត ដែលទទួលប្រភពទឹកពីផ្ទៃរងទឹកភ្លៀងភ្នំស្រួច ហូរចូលស្ទឹងស្វាស្ទាប់ ព្រមទាំងអាចបង្កើនការស្រោចស្រពបន្ថែមលើផ្ទៃដីបង្កបង្កើនផលស្រូវរដូវប្រាំងបានចំនួន ០៩ភូមិ ក្នុងឃុំក្រាំងដីវ៉ាយលើផ្ទៃដីសរុបចំនួន ១.៥០០ ហិកតា ។



*ឯកឧត្តម **លឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ចុះពិនិត្យស្ថានភាពប្រព័ន្ធធារាសាស្ត្រ នៅក្រាំងដីវ៉ាយ ឃុំក្រាំងដីវ៉ាយ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ*



តែដោយចរន្តទឹកមិនអាចហូរចូលតាមស្ទឹងស្ងាស្ងាប់ ដែលជាហេតុបណ្តាលអោយប្រព័ន្ធទាំងមូលត្រូវរងការខូចខាតទាំងស្រុង និងធ្វើអោយប្រជាកសិករជួបការលំបាកនូវការខ្វះខាតទឹកសំរាប់ការងារ បង្កបង្កើនផល ។

បច្ចុប្បន្នក្រសួងធនធានទឹក និងឧតុនិយម បានចុះអនុវត្តស្តារ ជួសជុល និងសាងសង់ សំណង់សិល្បៈការ និងស្តារប្រឡាយមេបន្តប្រវែង ១.៣០០ម៉ែត្រ លើប្រព័ន្ធស្រោចស្រពនេះ ។

ក្រោយពីស្តារ និងសាងសង់សំណង់សិល្បៈការរួច ប្រព័ន្ធស្រោចស្រពក្រាំងដីវ៉ាយអាចបង្កើនលទ្ធភាពស្រោចស្រពលើផ្ទៃដីបង្កបង្កើនផលស្រូវដើមរដូវលើកទី២ ដល់ប្រជាកសិករចំនួន ០៤ភូមិ គឺ ភូមិដូង ព្រៃទទឹង ដក់ពរ និងក្រាំងគរ ដែលអាចស្រោចស្រពបានចំនួន ៨០៥ ហិកតា និងដំណាំរួមផ្សំចំនួន ៤០ ហិកតា ព្រមទាំងសំរាប់ប្រើប្រាស់ក្នុងជីវភាពរស់នៅ និងសត្វពាហណៈនៅរដូវប្រាំងទៀតផង ។



ឯកឧត្តម ឈឹម គានហោ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ចុះពិនិត្យការដ្ឋាន និងជួបសំណេះសំណាលជាមួយប្រជាកសិករ និងព្រះសង្ឃ នៅស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ





សកម្មភាពគ្រឿងចក្រកំពុងជួសជុល និងទិដ្ឋភាពទំនប់ក្រាំងថីរ៉ាយ នៅស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ក្រោយពេលជួសជុល



ទិដ្ឋភាពតួទំនប់ក្រាំងថីរ៉ា នៅស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ក្រោយពេលសាងសង់រួច

ការងារស្តារអាងទឹកស្ទឹងស្នោង ស្ថិតនៅក្នុងស្រុកស្នោង ស្រុកកំពង់ស្វាយ និងស្រុកប្រាសាទឃាលំង្ក ខេត្តកំពង់ធំ





ស្ថានភាពទំនប់ស្ទឹងស្នោង
មិនទាន់ជួសជុល



សកម្មភាពគ្រឿងចក្រកំពុង
ជួសជុលទំនប់ស្ទឹងស្នោង



ឯកឧត្តមរដ្ឋមន្ត្រី **ឈឹម គានហោ** និងថ្នាក់ដឹកនាំក្រសួងចុះពិនិត្យ និងណែនាំការងារបច្ចេកទេស នៅការដ្ឋានស្ទឹងស្នោង



សកម្មភាពកំពុងជួសជុលឡើងវិញសំណង់ទ្វារទឹក ៣០ កញ្ញា ក្នុងប្រព័ន្ធធារាសាស្ត្រស្ទឹងស្នោង



ថ្នាក់ដឹកនាំក្រសួងធនធានទឹក និងឧតុនិយមចុះពិនិត្យការដ្ឋានសាងសង់ ប្រព័ន្ធធារាសាស្ត្រស្ទឹងស្នោង





សកម្មភាពរៀបចំគ្រឹះក្បាលសំណង់បង្ហៀរ







ឯកឧត្តមរដ្ឋមន្ត្រី លឹម គានហោ និងថ្នាក់ដឹកនាំក្រសួងធនធានទឹក និងឧតុនិយម ចុះពិនិត្យការងារជួសជុលសំណង់ទ្វារទឹកស្ទឹងស្នោង ស្ថិតនៅក្នុងស្រុកស្នោង ស្រុកកំពង់ស្វាយ ស្រុកត្រាសាទបាល័ង្ក ខេត្តកំពង់ធំ



ការងារសាងសង់ប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត ស្ថិតនៅស្រុកកំពង់ថ្ម ខេត្តកំពង់ធំ

ថ្នាក់ដឹកនាំក្រសួងធនធានទឹក និងឧតុនិយម ចុះពិនិត្យការងារសាងសង់ប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត នៅស្រុកំពង់ថ្ម ខេត្តកំពង់ធំ





សកម្មភាពរៀបថ្មធំតាមជើងទេរទំនប់



សកម្មភាពកិនបង្ហាប់ទំនប់ការពារទឹកជំនន់ខាងត្បូង ដោយប្រើគ្រឿងចក្រធុនធ្ងន់



សកម្មភាពលាយថ្មល្អិត និងស៊ីម៉ងត៍ ដើម្បីសាងសង់សំណង់ទ្វារទឹក



សកម្មភាពក្រុម PIU និងក្រុមអ្នកផ្តល់យោបល់ ចុះពិនិត្យ និងសិក្សាលើគំរោងស្ពារ និងសាសង់ប្រព័ន្ធធារាសាស្ត្រ ស្ទឹងជីនិត នៅស្រុកកំពង់ផ្ទ ខេត្តកំពង់ធំ



សកម្មភាពរៀបចំការងារដី
សំរាប់បាតគ្រឹះក្បាលសំណង់ដោះទឹក





សកម្មភាពការងារចាក់បេតុង និងរៀបចំសសៃដែកបាតគ្រឹះក្បាលសំណង់ដោះទឹក

ការងារស្តារ និងសាងសង់ប្រឡាយមេអូរដូនពៅ ឃុំស្រយូវ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ

ប្រឡាយមេអូរដូនពៅ ស្ថិតនៅក្នុងឃុំត្បូងក្រពើ និងឃុំស្រយូវ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ មានចំងាយ ១៦៥ គីឡូម៉ែត្រ ប៉ែកខាងជើងរាជធានីភ្នំពេញ។

បច្ចុប្បន្ននេះប្រឡាយមេអូរដូនពៅមិនអាចបំរើដល់ការស្រោចស្រពក្នុងការបង្កបង្កើនផលរបស់ប្រជាកសិករក្នុងមូលដ្ឋានបានគ្រប់គ្រាន់ទេ ដោយសារពោះប្រឡាយគោករាក់បណ្តាលអោយស្ទះចរន្តទឹកមិនអាចនាំទឹកទៅតាមតំរូវការដែលជាហេតុធ្វើអោយប្រជាកសិករ ជួបការលំបាកនូវការខ្វះទឹកសំរាប់បង្កបង្កើនផល និងប្រើប្រាស់ក្នុងជីវភាពរស់នៅក្នុងរដូវប្រាំង ។ ដោយទទួលបានការណែនាំ និងអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **ឈឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ក្រុមបច្ចេកទេសក្រសួងធនធានទឹក និងឧតុនិយម ដោយសហការជាមួយមន្ទីរជំនាញខេត្តកំពង់ធំបានចាប់ផ្តើមស្តារ និងសាងសង់ប្រឡាយមេ អូរដូនពៅ នៅថ្ងៃទី ២៤ ខែ មិនា ឆ្នាំ ២០០៥។

ប្រឡាយមេ អូរដូនពៅ អាចផ្តល់ប្រយោជន៍ដល់ប្រជាកសិករចំនួន ១៨ ភូមិ ដែលរស់ នៅក្នុងឃុំត្បូងក្រពើ និងឃុំស្រយូវ របស់ស្រុកស្ទឹងសែនអាចស្រោចស្រពលើផ្ទៃដីបន្ថែម ៣.000 ហិកតា និងអាចបង្កើន ទិន្នផលពី ៨00 គក្រ ដល់ ១,៥0 តោន ក្នុង ១ ហិកតា ជាពិសេសវាអាចរក្សាទឹកបានគ្រប់គ្រាន់សំរាប់ប្រើប្រាស់ក្នុងជីវភាពរស់នៅរបស់ប្រជាជននិងសត្វពាហនៈក្នុងរដូប្រាំងទៀតផង។





ឯកឧត្តម **ឈឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ព្រមទាំងថ្នាក់ដឹកនាំក្រសួងចុះពិនិត្យ ការងារស្តារ និងសាងសង់ប្រឡាយមេអូរដូនពៅ នៅខេត្តកំពង់ធំ



ឯកឧត្តម **ឈឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម ចុះពិនិត្យបច្ចេកទេសដល់ការដ្ឋានផ្ទាល់លើការងារស្តារ និងសាងសង់ប្រព័ន្ធប្រឡាយមេអូរដូនពៅ ខេត្តកំពង់ធំ



ស្ថានភាពប្រឡាយមេអូរដូនពៅ មុនពេលស្តារ



ឯកឧត្តមរដ្ឋមន្ត្រី **ឈឹម គានហោ** និងថ្នាក់ដឹកនាំក្រសួងធនធានទឹក និងឧតុនិយម ចុះពិនិត្យការងារស្តារប្រឡាយមេអូរដូនពៅ



សកម្មភាពគ្រឿចក្រកំពុងស្តារប្រឡាយមេអូរដូនពៅ



ឯកឧត្តមរដ្ឋមន្ត្រី **ឈឹម គានហោ** និងថ្នាក់ដឹកនាំក្រសួងធនធានទឹក និងឧតុនិយម ចុះពិនិត្យការងារស្តារប្រឡាយមេអូរដូនពៅ និងជួបសំណេះសំណាលជាមួយបងប្អូនប្រជាកសិករ



ប្រឡាយមេ អូរដូនពៅ ក្រោយពេលស្តាររួច



សកម្មភាពគ្រឿងចក្រជួសជុលទំនប់បឹងខ្វែក ស្ថិតនៅឃុំតាំងក្រសាំង ស្រុកសន្ទុក ខេត្តកំពង់ធំ

ការចារស្តារប្រព័ន្ធប្រឡាយពងទឹក ទៅភូមិពងទឹក ឃុំស្តេចគង់ខាងជើង ស្រុកបន្ទាយមាស ខេត្តកំពត



សកម្មភាពឯកឧត្តម លឹម គានហោ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម អមដំណើរដោយឯកឧត្តម អភិបាលរងទី១ ខេត្តកំពត និងថ្នាក់ដឹកនាំក្រសួង ចុះពិនិត្យការងារជីកប្រឡាយពងទឹក និងណែនាំពីគំរោងស្តារ និងជួសជុលប្រព័ន្ធប្រឡាយពងទឹក ស្ថិតក្នុង ភូមិពងទឹក ឃុំស្តេចគង់ខាងជើង ស្រុកបន្ទាយមាស ខេត្តកំពត





សកម្មភាពថ្នាក់ដឹកនាំក្រសួងធនធានទឹក និងឧតុនិយម ចុះពិនិត្យ និងពិភាក្សា ក្នុងការប្តូរលូចាស់ ដោយសាងសង់លូថ្មីឆ្លងកាត់ ប្រឡាយមេពងទឹក ដែលជាអំណោយផ្ទាល់របស់ឯកឧត្តម **ឈឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ក្នុងភូមិពងទឹក ឃុំស្តេចគង់ខាងជើង ស្រុកបន្ទាយមាស ខេត្តកំពត







សកម្មភាពកំពុងសាងសង់ដាក់លូជ្រុងឆ្លងកាត់ប្រឡាយមេពងទឹក



ទិដ្ឋភាពសំណង់លូឆ្លងកាត់ប្រឡាយមេពងទឹក ដែលជាអំណោយផ្ទាល់របស់ឯកឧត្តម **ឈឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ស្ថិតក្នុងភូមិពងទឹក ឃុំស្តេចគង់ខាងជើង ស្រុកបន្ទាយមាស ខេត្តកំពត ក្រោយពេលសាងសង់រួច



សកម្មភាពថ្នាក់ដឹកនាំក្រសួងធនធានទឹក និងឧតុនិយម ចុះពិនិត្យប្រឡាយពងទឹក ស្ថិតក្នុងឃុំស្តេចគង់ខាងជើង ស្រុកបន្ទាយមាស ខេត្តកំពត មុនពេលស្តារ



សកម្មភាពគ្រឿងជីកប្រឡាយពងទឹក ស្ថិតក្នុងឃុំស្តេចគង់ខាងជើង ស្រុកបន្ទាយមាសខេត្តកំពត



សកម្មភាពកសិករកំពុង ចូលរួមកាយគ្រួសក្រហមតាមភ្លឺប្រឡាយពងទឹក ស្ថិតក្នុងឃុំស្តេចគង់ខាងជើង ស្រុកបន្ទាយមាសខេត្តកំពត



ថ្នាក់ដឹកនាំក្រសួងធនធានទឹក និងឧតុនិយម ចុះពិនិត្យសិក្ខានុពលទឹក ដែលប្រឡាយស្រូបយកសំរាប់ ស្រោចស្រពដល់ផ្ទៃដីដាំដុះរបស់ប្រជាកសិករ



ប្រឡាយមេពងទឹក ស្ថិតក្នុងឃុំស្តេចគង់ខាងជើង ស្រុកបន្ទាយមាសខេត្តកំពតក្រោយពេលជួសជុលរួច

ឯកឧត្តមរដ្ឋមន្ត្រី **ឈឹម គានហោ** ចុះពិនិត្យសកម្មភាពការងារជីកប្រឡាយ នៅស្ថានីយបូមទឹកសម្តេច **ហ៊ុន សែន** ទី ៤៥ ស្រុកទូកមាស ខេត្តកំពត





សកម្មភាពជីកប្រឡាយមេមួយខ្សែដែលមានប្រវែង ១៩៥០ ម៉ែត្រ នៅស្ថានីយបូមទឹកសម្តេច **ហ៊ុន សែន** ទី ៤៥ នៅស្រុកទូកមាស ខេត្តកំពត

ឯកឧត្តមរដ្ឋមន្ត្រី **ឈឹម គានហោ** ចុះពិនិត្យស្ថានីយបូមទឹកសម្តេច **ហ៊ុន សែន** ទី ៤៥ ស្រុកទូកមាស ខេត្តកំពត





លទ្ធភាពបូមទឹករបស់ស្ថានីយបូមទឹកសម្តេច **ហ៊ុន សែន** ទី ៤៥ ក្នុងស្រុកទូកមាស ខេត្តកំពត

ការចាស្តារ និងកសាងទំនប់អូរថ្ម នៅភូមិព្រៃតាកុយ សង្កាត់ពងទឹក ខណ្ឌដំណាក់ចង្អើរ ក្រុងកែប



ឯកឧត្តម **លឹម គានហោ** រដ្ឋមន្ត្រីក្រសួង ធនធានទឹក និងឧតុនិយមចុះពិនិត្យការងារ សហគមន៍កសិករប្រើប្រាស់ទឹក នៅទំនប់ភ្នំវល្លិ ឃុំចំការពង សង្កាត់ពងទឹក ខណ្ឌដំណាក់ចង្អើរ ក្រុងកែប





ឯកឧត្តមរដ្ឋមន្ត្រី លឹម គានហោ ចុះពិនិត្យការងារសាងសង់ទំនប់ដី (អូរថ្ម) សង្កាត់ពងទឹក ខណ្ឌ ចំណាក់ចង្អើរ ក្រុងកែប



សកម្មភាពគ្រឿងចក្រកំពុងសាងសង់ទំនប់ដី (អូរថ្ម) សង្កាត់ពងទឹក ខណ្ឌដំណាក់ចង្អើរ ក្រុងកែប ចំងាយ ១.២០០ម





ទំនប់ដី (អូរថ្ម) ភូមិព្រៃតាកុយ សង្កាត់ពងទឹក ខណ្ឌដំណាក់ចង្អើរ ក្រុងកែប ចំងាយ ១២០០ម ក្រោយពេលជួសជុលរួច



ថ្នាក់ដឹកនាំក្រសួងធនធានទឹក
និងឧតុនិយម ចុះពិនិត្យការងារ
កំពុងចំណើរការសាងសង់
សំណង់បង្ហៀរក្រោមស្ពានទំនប់
អូរថ្ម ស្ថិតនៅភូមិព្រៃតាកុយ
សង្កាត់ពងទឹក ខណ្ឌដំណាក់
ចង្អើរ ក្រុងកែប





សកម្មភាពកំពុងសាងសង់សំណង់បង្ហៀរក្រោមស្ពានទំនប់អូរថ្ម ស្ថិតនៅ ភូមិព្រៃតាកុយ សង្កាត់ពងទឹក
ខណ្ឌដំណាក់ចង្អើរ ក្រុងកែប

សំណង់បង្ហៀរក្រោម
ស្ពានទំនប់អូរថ្ម
ស្ថិតនៅក្នុងភូមិ
ព្រៃតាកុយ
សង្កាត់ពងទឹក
ខណ្ឌដំណាក់ចង្អើរ
ក្រុងកែប



ប្រព័ន្ធស្រោចស្រពដំណាក់អំពិល ស្ថិតក្នុងភូមិដំណាក់អំពិល ឃុំចំរើនផល និងឃុំលលកស ស្រុកសំពៅមាស និងស្រុកបាកាន ខេត្តពោធិ៍សាត់







ឯកឧត្តម **ឈឹម គានហោ** ចុះពិនិត្យស្ថានភាពសំណង់ ទ្វាទឹកដំណាក់អំពិល ស្ថិតក្នុងភូមិដំណាក់អំពិល ឃុំចំរើនផល និងឃុំលលកស ស្រុកសំពៅមាស និងស្រុកបាកាន ខេត្តពោធិ៍សាត់ ដែលត្រូវកំទេចចោល ដើម្បីសាងសង់ឡើងវិញ



ទិដ្ឋភាពប្រភពទឹកស្ទឹងពោធិ៍សាត់ ស្រុកសំពៅមាស និងស្រុកបាកាន ខេត្តពោធិ៍សាត់



ឯកឧត្តម **ឈឹម គានហោ** ចុះពិនិត្យសកម្មភាពស្តារប្រព័ន្ធស្រោចស្រពដំណាក់អំពិល ស្ថិតក្នុងភូមិដំណាក់អំពិល ឃុំចំរើនផល និងឃុំលលកស ស្រុកសំពៅមាស និងស្រុកបាកាន ខេត្តពោធិ៍សាត់



ឯកឧត្តមរដ្ឋមន្ត្រីពិនិត្យទីតាំងស្តារប្រព័ន្ធស្រោចស្រពដំណាក់អំពិលនៅឃុំចំរើនផល ឃុំលលកស ស្រុកសំពៅមាស និងស្រុកបាកាន ខេត្តពោធិ៍សាត់





ស្ថានភាពប្រឡាយរង ស្ថិតក្នុងឃុំអូរសណ្តាន់ ស្រុកក្រគរ ខេត្តពោធិ៍សាត់ មុនពេលស្តារ និងក្រោយពេលស្តារ

ស្ថានភាពប្រព័ន្ធស្រោចស្រពដំណាក់អំពិល នៅ
ឃុំចំរើនផល.ឃុំលលកស ស្រុកសំពៅមាស
និងស្រុកបាកាន មុនពេលស្តារ







សកម្មភាពគ្រឿងចក្រកំពុងដំណើរការស្តារប្រព័ន្ធស្រោចស្រពដំណាក់អំពិល នៅខេត្តពោធិ៍សាត់



ស្ថានភាពប្រព័ន្ធស្រោចស្រពដំណាក់អំពិល ក្រោយពេលស្តាររួច

ប្រព័ន្ធស្រោចស្រពសន្ទែ នៅឃុំសន្ទែ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់



ឯកឧត្តម **ឈឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ចុះពិនិត្យការងារជួសជុលសំណង់ស្ថានីយ ស្ថិតនៅឃុំសន្ទែ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់



ស្ថានភាពសំណង់ស្ថានីយ ដែលទទួលរងនូវការខូចខាត



ឯកឧត្តមរដ្ឋមន្ត្រីចុះត្រួតពិនិត្យសកម្មភាពជួសជុលសំណង់ស្ថានីយ ស្ថិតនៅឃុំសន្ទែ ស្រុកភ្នំក្រវាញ





សំណង់ស្ថានីយ ស្ថិតនៅឃុំសន្ទ្រែ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ក្រោយពេលជួសជុល



សកម្មភាពស្តារប្រឡាយសន្ទ្រែ
ស្ថិតនៅឃុំសន្ទ្រែ ស្រុកភ្នំក្រវាញ
ខេត្តពោធិ៍សាត់

ប្រឡាយសន្ទ្រែ
ក្រោយពេលស្តាររួច





សកម្មភាពគណៈប្រតិភូក្រសួងធនធានទឹក និងឧតុនិយម ចុះពិនិត្យលើប្រព័ន្ធប្រឡាយមេ នៃប្រព័ន្ធធារាសាស្ត្រអូររកា ក្នុងស្រុកសំពៅមាស ខេត្តពោធិ៍សាត់



ការងារកំទេចចោលសំណង់ចាស់ ដើម្បីធ្វើសំណង់ទ្វារទឹកថ្មី ទំនើបបំពាក់អោយប្រព័ន្ធធារាសាស្ត្រអូររកា ស្ថិតក្នុងស្រុកសំពៅមាស ខេត្តពោធិ៍សាត់



សកម្មភាពការងារកំពុងសាងសង់ប្រព័ន្ធស្តាក់ទឹក ក្នុងប្រព័ន្ធធារាសាស្ត្រអូររកា ស្ថិតក្នុងស្រុកសំពៅមាស ខេត្តពោធិ៍សាត់



សកម្មភាពការងារសាងសង់លូជ្រុង និងធ្វើស្ពាន ក្នុងប្រព័ន្ធប្រឡាយក្តីខ្វាយ ក្នុងប្រព័ន្ធធារាសាស្ត្រអូររកា ស្ថិតក្នុងស្រុកសំពៅមាស ខេត្តពោធិ៍សាត់

ឯកឧត្តមរដ្ឋមន្ត្រី លឹម គានហោ រួមដំណើរដោយឯកឧត្តមឯកអគ្គរាជទូតជប៉ុន និងថ្នាក់ដឹកនាំក្រសួង ចុះត្រួតពិនិត្យ និងសិក្សាលើតំរោងស្តារប្រព័ន្ធធារាសាស្ត្រនៅខេត្តបាត់ដំបង







ឯកឧត្តម លឹម គានហោ និងឯកឧត្តមឯកអគ្គរាជទូតជប៉ុន ចុះត្រួតពិនិត្យស្ថានភាពប្រឡាយ និងសំណង់ធារាសាស្ត្រ ដែលត្រូវស្តារ និងជួសជុលឡើងវិញនៅឃុំព្រែកជីក ស្រុកមោងឬស្សី ខេត្តបាត់ដំបង



ស្ថានភាពគ្រឿងចក្រកំពុងស្តារប្រឡាយស្នួលទ្រែត ស្ថិតនៅឃុំព្រែកជីក ស្រុកចោងឬស្សី ខេត្តបាត់ដំបង



ប្រឡាយស្នួលទ្រែត ក្រោយពេលស្តាររួច

ស្ថានីយត្អាតពង ស្ថិតនៅឃុំវត្តតាមិម ស្រុកសង្កែ ខេត្តបាត់ដំបង

" ស្ថានីយ ហ៊ុន សែន ទី ៤៧ "









ឯកឧត្តមរដ្ឋមន្ត្រី លឹម គានហោ និងថ្នាក់ដឹកនាំក្រសួងធនធានទឹក និងឧតុនិយមអញ្ជើញចុះពិនិត្យការងារកសាងស្ថានីយត្អាតពង (ស្ថានីយ ហ៊ុន សែន ទី ៤៧) ស្ថិតនៅឃុំតាមិម ស្រុកសង្កែ ខេត្តបាត់ដំបង

ការងារអភិវឌ្ឍន៍តំបន់ស្រោចស្រពក្រហម ក ស្ថិតនៅព្រំប្រទល់ស្រុកអូររាំងឪ ខេត្តកំពង់ចាម និងស្រុកកញ្ជ្រៀច ខេត្តព្រៃវែង





*សម្តេច **ហ៊ុន សែន** មានមតិសំណេះសំណាលជាមួយប្រជាកសិករ នៅតំបន់ អភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពក្រហម ក*

តំបន់អភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពក្រហម ក ស្ថិតនៅក្នុងឃុំចក ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង មានចម្ងាយប្រមាណ ១៨០គ.ម ខាងកើតរាជធានីភ្នំពេញ ។ ប្រព័ន្ធស្រោចស្រពនេះកសាងនៅក្នុងរបប ប៉ុល ពត ដែលទទួលប្រភពទឹកពីផ្នែរងទឹកភ្លៀងស្រុកអូររាំងឪ និងស្រុកត្បូងឃ្មុំខេត្តកំពង់ចាម តាមប្រឡាយមេ ១១ មករា បន្ថែមលើផ្ទៃដីបង្ក-បង្កើនផលស្រូវរដូវវស្សាបានចំនួន ២២ភូមិ ក្នុងឃុំចំនួន ៣ គឺ ឃុំចក ឃុំគោកខាងលិច និងឃុំគោកខាងកើត ដែលមានផ្ទៃដីសរុបចំនួន ២.៨០២ ហិកតា ។

ផ្អែកលើតំបន់នេះពុំមានអាងស្តុកទឹកសំរាប់ជួយសង្គ្រោះស្រូវរដូវស្បា នៅដើមរដូវ ចុងរដូវ និងពុំអាចដំណើរការស្រោចស្រពបានគ្រប់គ្រាន់ជូនប្រជាកសិករ គឺចាំបាច់ត្រូវសាងសង់នូវសំណង់ស្តាក់ទឹក សំណង់បង្ហៀរ និងសំណង់ចែកចាយដើម្បីរក្សាកំពស់ទឹកនៅក្នុងប្រឡាយមេ ដើម្បីផ្តល់អោយប្រឡាយរង និងប្រឡាយស្រោចស្រពនៅដើមរដូវរស្បា និងចុងរដូវ និងពេលជួបគ្រោះរាំស្ងួត ។

សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា អមដំណើរដោយឯកឧត្តម **លឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ព្រមទាំងមន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាល បានចុះពិនិត្យតំបន់អភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពក្រហម ក ហើយបានបញ្ជាអោយធ្វើការអភិវឌ្ឍន៍តំបន់នេះតាមរយៈក្រសួងធនធានទឹក និងឧតុនិយម ។ ឆ្លងតាមការចុះពិនិត្យផ្ទាល់ដល់មូលដ្ឋានរបស់ក្រុមបច្ចេកទេសក្រសួងធនធានទឹក និងឧតុនិយម និងធ្វើការពិភាក្សាជាមួយមន្ទីរធនធានទឹក និងឧតុនិយមខេត្តព្រៃវែង និងខេត្តកំពង់ចាមរួមទាំងអាជ្ញាធរដែនដី លទ្ធភាពក្រោយពេលដែលធ្វើការសាងសង់ និងជួសជុលរួច ប្រព័ន្ធស្រោចស្រពក្រហម ក អាចធ្វើអោយប្រជាកសិករចំនួន ២២ភូមិ របស់ឃុំ ទាំង ៣ ខាងលើអាចស្រោចស្រពលើផ្ទៃដីបង្កបង្កើន ផលស្រូវនៅរដូវរស្បាបានចំនួន ២.៨០២ ហិកតា ជាលក្ខណៈបង្ហូរសំរាប់ស្រូវរស្បា និងជួយបង្កើនទិន្នផល អោយបានប្រសើរជាងមុន ។



ឯកឧត្តម **លឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយមបង្ហាញគំរោងអភិវឌ្ឍន៍តំបន់ប្រព័ន្ធស្រោចស្រពក្រហម ក ជូនដល់សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា



ឯកឧត្តម **លឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ធ្វើសេចក្តីរាយការណ៍ជូនសម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ស្តីពីការងារស្តារ និងកសាងប្រព័ន្ធស្រោចស្រពក្រហម ក



ប្រជាកសិករអបអរសាទរទទួលសម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ក្នុងឱកាសចុះត្រួតពិនិត្យតំបន់អភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពក្រហម ក នៅស្រុកកញ្ច្រៀច ខេត្តកំពង់ចាម



ប្រព័ន្ធប្រឡាយក្រហម ក ដែលពុំទាន់ទទួលការស្តារ និងកសាងឡើងវិញ



សកម្មភាពស្តារ និងសាងសង់ទំនប់ ប្រឡាយ ក្រហម ក

សកម្មភាព
សាងសង់
សំណង់បង្ហៀរ
នៅតំបន់
អភិវឌ្ឍន៍
ក្រហម ក





សំណង់បង្ហៀរនៅតំបន់អភិវឌ្ឍន៍ក្រហម ក ក្រោយពេលសាងសង់

ការងារជួសជុលទំនប់ ប្រឡាយ ក្បាលដា ស្ថិតក្នុងឃុំល្បែង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម







សកម្មភាពកំពុងជួសជុល តួទំនប់ ប្រឡាយក្បាលដា ស្ថិតក្នុងឃុំល្បែង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម

សកម្មភាពថ្នាក់ដឹកនាំក្រសួងធនធានទឹក
និងឧតុនិយម ចុះពិនិត្យការងារជួសជុល
តូទំនប់ ប្រឡាយក្បាលរា ស្ថិតក្នុង
ឃុំល្វៀង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម







តូទំនប់ក្បាលរា ក្រោយពេលជួសជុលរួច

ការងារស្តារប្រឡាយអូរបឹងបបុស ស្ថិតក្នុងឃុំរកាខ្ទុរ ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម





ស្ថានភាពទំនប់ប្រឡាយអូរបឹងបបុស ស្ថិតក្នុងឃុំរកាខ្ទុរ ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម មុនពេលស្តារ



សកម្មភាពកំពុងស្តារប្រឡាយ អូរបឹងបបុស នៅខេត្តកំពង់ចាម



សកម្មភាពកំពុងស្តារប្រឡាយអូរបឹងបបុស

ឯកឧត្តម ហ៊ុន ណេង និងឯកឧត្តម ជា សុផារ៉ា
អមដំណើរដោយគណៈប្រតិភូចុះត្រួពិនិត្យការងារធារាសាស្ត្រ



គណៈប្រតិភូពិនិត្យតំរៀងការងារ
ស្តារប្រឡាយមេ ស្ថិតក្នុងឃុំរកាខ្ទុរ
ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម





សកម្មភាពគណៈប្រតិភូចុះពិនិត្យការងារ
ស្តារប្រឡាយមេ ស្ថិតក្នុងឃុំរកាខ្ទុរ
ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម





សកម្មភាពគ្រឿងចក្រកំពុងស្តារ
ប្រឡាយមេ ស្ថិតក្នុង ឃុំរកាខ្ទុរ
ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម

ការចារជួសជុល ទំនប់ផ្តៅជុំ ស្ថិតក្នុងស្រុកជើងព្រៃ និងស្រុកឃាឃាយ ខេត្តកំពង់ចាម

ទំនប់ផ្តៅជុំ ដែលរងនូវការ
ខូចខាត និងសក្ឋភាព
កំពុងជួសជុល









ថ្នាក់ដឹកនាំកសួង
ធនធានទឹក និង
ឧតុនិយម ចុះ
ពិនិត្យទំនប់ផ្តៅជុំ
ក្រោយពេល
ជួចជុល្សូច

ការងារស្តារ ស្ទឹងស្វាយចេក ក្នុងស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ







ឯកឧត្តម **ឈឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងថ្នាក់ដឹកនាំក្រសួង ចុះពិនិត្យភូមិសាស្ត្រ និងណែនាំពីតំរោងស្តារ ស្ទឹងស្វាយចេក

ស្ថានភាពស្ទឹងស្វាយចេកមិនទាន់ស្តារ ស្ថិតក្នុង
ឃុំរលួស ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ





សកម្មភាពកំពុងស្តារ ស្ទឹងស្វាយចេក





ឯកឧត្តមរដ្ឋមន្ត្រី **ឈឹម គានហោ** ពិនិត្យសកម្មភាពគ្រឿងចក្រកំពុងស្តារស្ទឹងស្វាយចេក ស្ថិតក្នុងឃុំរលួស
ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ

ស្ទឹងស្វាយចេក ស្ថិតក្នុងឃុំរលួស ស្រុកស្វាយចេក
ខេត្តបន្ទាយមានជ័យ ក្រោយពេលស្តាររួច



ឯកឧត្តមរដ្ឋមន្ត្រី បង្ហាញពីទីតាំង ដែលត្រូវលើក ទំនេរ កសាង ប្រព័ន្ធធារាសាស្ត្រ បន្ថែមសំរាប់ ផ្គត់ផ្គង់ទឹកដល់ ស្ទឹងស្វាយចេក





សកម្មភាពឯកឧត្តម **កែ គឹមយ៉ាន** អមដំណើរ ដោយគណៈប្រតិភូចុះត្រួតពិនិត្យការងារស្តារ ស្ទឹងស្វាយចេក



អាងស្តុកទឹកអន្លង់រត់សំរាប់ផ្គត់ផ្គង់ទឹកដល់ស្ទឹងស្វាយចេក



ស្ថានភាពប្រឡាយអន្លង់រត់ ក្រោយពេលស្តាររួច ស្ថិត ក្នុងឃុំរលួស ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ

ប្រព័ន្ធស្រោចស្រពអាងទឹកត្រពាំងថ្មស្ថិតក្នុងស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ



ប្រព័ន្ធស្រោចស្រពអាងទឹកត្រពាំងថ្មស្ថិតនៅក្នុងឃុំចំនួន ៥ គឺឃុំប៉ោយ ចារ ឃុំពន្លៃ ឃុំស្រែជីក ឃុំរហាល និង ឃុំទ្បែនកម្ម ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ មានចម្ងាយប្រមាណ ៦៦គីឡូម៉ែត្រ ប៉ែកឥសានទីរួមខេត្តបន្ទាយមានជ័យ (ស្រុកសិរីសោភ័ណ)។

ទំនប់នេះមានអាយុកាលប្រមាណ ៩០០ ឆ្នាំហើយពោលគឺត្រូវបានកសាងឡើងតាំងពីសម័យអង្គរមកម្លេះ។ ពីដំបូងឡើយទំនប់នេះគឺជាផ្លូវលំដែលមានទទឹង ៤ ម៉ែត្រ និងកំពស់ ២ ម៉ែត្រ តភ្ជាប់ទៅភូមិត្រពាំងថ្ម និងភូមិពន្លៃ ស្រុកភ្នំស្រុក កាត់តាមតំបន់ ទំនាបវាលស្រែ ។



ក្នុងរបបប៉ុលពតអំឡុងឆ្នាំ ១៩៧៦-១៩៧៨ បានប្រែក្លាយផ្លូវលំបុរាណនេះជាទំនប់អាងត្រពាំងថ្ម ដែលមានបណ្តោយសរុបប្រវែង ១៨.២ គីឡូម៉ែត្រ ព្រមទាំងប្រឡាយស្រោចស្រព និងសំណង់ទ្វារទឹក តូច-ធំ ចំនួន ៨ កន្លែង ដែលពុំទាន់សាងសង់រួច ។ ក្រោយថ្ងៃរំដោះ ៧មករា ឆ្នាំ ១៩៧៩ ដល់ឆ្នាំ ១៩៩៨ ក្នុងជំនាន់អតីតរដ្ឋកម្ពុជា អាងទឹកត្រពាំងថ្មទទួល រងនូវការខូចខាតបន្ថែមទៀតដោយសារសង្គ្រាមស៊ីវិល ទាំងទំនប់អាង ទាំងប្រព័ន្ធប្រឡាយ និងសំណង់ទ្វារទឹក ហើយត្រូវបានជួសជុលត្រឹមតែជាទ្រង់ទ្រាយតូច ។ ប្រព័ន្ធស្រោចស្រពអាងទឹកត្រពាំងថ្មជាប្រព័ន្ធ ទំនប់អាងស្តុកទឹក ដែលមានប្រភពទឹកពីព្រែកស្រែមេម៉ាយ ព្រែកកន្លង់ធំ និងទឹកភ្លៀង ដែលមានផ្ទៃរងទឹកភ្លៀង ប្រមាណ ១៨.៥ គីឡូម៉ែត្រ និងផ្ទៃដីចំណុះត្រពាំងប្រមាណ ៥.២០២ ហិកតា ដែលមានក្រិតកំពស់ ១៩.៥០ ម៉ែត្រ ក្នុងនោះចំណុះអាងអតិបរិមាដែលមានស្រាប់មុនការជួសជុលស្តារឡើងវិញប្រមាណ ២.៧៧៥ ហិកតា ដែលមានក្រិត កំពស់ ១៧.៧០ម៉ែត្រ និងមានបរិមាណធារទឹកអតិបរិមាដែលមានក្រិត ១៨.៥០ម៉ែត្រ មានប្រមាណ ១៤១.៥០៧.០០០ ម៉ែត្រត្រីគុណ ។ តាមការប៉ាន់ស្មានក្រោយពីការជួសជុលឡើងវិញ បរិមាណទឹកមានគ្រប់គ្រាន់ និងមានលទ្ធភាពធានាដល់ការស្រោចស្រពលើផ្ទៃដីស្រូវប្រាំងប្រមាណ ៧.០០០ ហិកតា ព្រមទាំងធានាដល់ការបង្កបង្កើនផលលើកទី ២ នៅរដូវវស្សារបស់កសិករបានប្រមាណ ១១.០០០ហិកតា ថែមទៀត ដោយទទួលលទ្ធផល ២តោនក្នុង ១ហិកតា ដែលពីមុនស្រោចស្រពបានត្រឹមតែ ៣.០០០ ហិកតា និងទទួលទិន្នផលបានតែ ១.២ តោន ក្នុង ១ហិកតា ប៉ុណ្ណោះ ។ គំរោងជួសជុលឡើងវិញប្រព័ន្ធស្រោចស្រពអាងទឹកត្រពាំងថ្ម ត្រូវបានដំណើរការចាប់ពីថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៤ និងបានបញ្ចប់ជាស្ថាពរនាថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០៤ ក្រោមជំនួយឥតសំណងរបស់រាជរដ្ឋាភិបាលជប៉ុន ដោយប្រើប្រាស់ទឹកប្រាក់សរុបចំនួន ១.៧១០.៩២៨,២៦ ដុល្លារអាមេរិក ។





ទំនប់អាងទឹកត្រពាំងថ្មមុនពេលជួសជុល



ថ្នាក់ដឹកនាំក្រសួងជួបសំណេះសំណាល និងណែនាំពីបច្ចេកទេសដល់មន្ត្រីជំនាញ

សកម្មភាពមន្ត្រីជំនាញកំពុងត្រួតពិនិត្យ
ការិតកំពស់បាតសំណង់ក្នុងពេលសាងសង់





សកម្មភាពចាក់ និងបង្ហាប់បេតុង
បាតសំណង់បញ្ចេញទឹក



ឯកឧត្តមរដ្ឋមន្ត្រី លឹម គានហោ ចុះពិនិត្យសំណង់ទ្វារទឹកស្ល័យប្រវត្តអាងទឹកត្រពាំងថ្ម
ក្រោយពេលជួសជុលរួចជាស្ថាពរ

សំណង់ទ្វាទឹកស្ល័យប្រវត្តអាងទឹក
ត្រពាំងថ្ម ក្រោយពេលជួសជុលរួចជាស្ថាពរ





សំណង់បញ្ចេញទឹកកំពុង
ដំណើរការសាងសង់



ថ្នាក់ដឹកនាំក្រសួងធនធានទឹក និងឧតុនិយម ចុះពិនិត្យការងារសំណង់ជី

សកម្មភាពបង្ហាប់ជើងទំនប់ដោយគ្រឿងចក្រធុនធ្ងន់





សកម្មភាពរៀបថ្ម និងដាំស្មៅការពារជើងទំនប់

ទំនប់អាងទឹកត្រពាំងថ្ម ត្រូវបានសាងសង់រួចជាស្ថាពរ



សកម្មភាពការងារស្ដារ និងជួសជុល ប្រព័ន្ធប្រឡាយ អូរអកអំបុក ១+២ ក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង



សកម្មភាពឯកឧត្តម ឈឹម គានហោ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងថ្នាក់ដឹកនាំក្រសួងចុះពិនិត្យភូមិសាស្ត្រ ការជ្រាតសាងសង់ និងណែនាំពីទំរង់ ស្ដារនិងជួសជុលប្រព័ន្ធប្រឡាយអូរអកអំបុក ស្ថិតក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង



ទិដ្ឋភាពប្រពន្ធប្រឡាយអូរអកអំបុក១
ស្ថិតក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង



សកម្មភាពគ្រឿងចក្រកំពុងសាងសង់
ប្រព័ន្ធប្រឡាយអូរអកអំបុក១

សំណង់សិល្បៈការក្រោមស្ពាន
នៅប្រព័ន្ធប្រឡាយអូរអកអំបុក២



សកម្មភាពស្តារប្រឡាយអូរអកអំបុក២ ស្ថិតនៅ ភូមិកំពង់ស្វាយកើត ឃុំកំពង់ត្របែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង







ប្រឡាយអូរអកអំបុក២ ក្រោយពេលស្តារ

ការចារជួសជុលទំនប់អាងទឹកពោធិ៍ប្ងរី ស្ថិតក្នុងស្រុកព្រះស្តេច ខេត្តព្រៃវែង



ទិដ្ឋភាពទំនប់អាងទឹកពោធិ៍ប្ងរី មុនពេលជួសជុល





សកម្មភាពកំពុងជួសជុល និងរៀបចំធំ
ការពារ ជំរាលទំនប់អាងទឹកពោធិ៍ប្ងរី

ទំនប់អាងទឹក
ពោធិ៍ ប្ងរី
ក្រោយពេល
ជួសជុលរួច







សកម្មភាពគ្រឿងចក្រកំពុងស្តារប្រឡាយទឹកព្រែកណ្តៀង ស្ថិតក្នុងស្រុកពាមរក៏ ខេត្តព្រៃវែង





សកម្មភាពគ្រឿងចក្រកំពុងជួសជុលទំនប់បារាយណ៍អណ្តែត ស្ថិតក្នុងឃុំបារាយណ៍ ស្រុកកំពង់លាវ ខេត្តព្រៃវែង



សំណង់ក្បាលហុងទឹក
ប្រឡាយព្រែកណ្តៀង
ស្ថិតក្នុងឃុំព្រែកណ្តៀង
ស្រុកពាមរ៉ៃ ខេត្តព្រៃវែង

ការចោរសោរសង់ទំនប់ ខ្ពបត្រពែក ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ







សកម្មភាពការងារគ្រឿងចក្រលើកទំនប់ខ្ពបត្រពែក ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ



ឯកឧត្តមរដ្ឋមន្ត្រី និងថ្នាក់ដឹកនាំក្រសួងធនធានទឹក និងឧតុនិយមចុះពិនិត្យការជួនសាងសង់សំណង់ទំនប់ខ្ជបត្រពែក ស្ថិតនៅក្នុងឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ





សកម្មភាពកំពុងសាងសង់សំណង់ទ្វារទឹកខ្ជបត្រពែក



សកម្មភាពចុះពិនិត្យគ្រឿងចក្រកំពុងស្តារប្រឡាយព្រៃខ្ចា ស្ថិតក្នុងឃុំព្រៃខ្ចា ស្រុកកោះអណ្តែត ខេត្តតាកែវ



ប្រឡាយព្រៃខ្ចា ក្រោយពេលស្តាររួច ស្ថិតក្នុងឃុំព្រៃខ្ចា ស្រុកកោះអណ្តែត ខេត្តតាកែវ

ការចារជួសជុល ទំនប់ពេជ្រសារ ស្ថិតក្នុងស្រុកកោះអណ្តែត ខេត្តតាកែវ



សកម្មភាពកំពុងជួសជុល ទំនប់ពេជ្រសារ



ទំនប់ពេជ្រសារ ក្រោយពេលជួសជុល



សំណង់បំពង់លូឆ្លងកាត់ទំនប់ពេជ្រសារ ក្រោយពេលជួសជុល

ការងារជួសជុល និងស្តារឡើងវិញប្រព័ន្ធធារាសាស្ត្រ ក្នុងស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង







សកម្មភាពកំពុងស្តារប្រព័ន្ធប្រឡាយមេ
និងប្រឡាយរងទី ២ ក្នុងប្រព័ន្ធធារាសាស្ត្រ
ជប់ព្រីង ស្ថិតក្នុងស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង



ប្រព័ន្ធប្រឡាយមេ
និងប្រឡាយរងទី
២ ក្នុងប្រព័ន្ធ
ធារាសាស្ត្រជប់ព្រីង
ក្រោយពេលស្តាររួច





សកម្មភាពចុះសិក្សាលើប្រព័ន្ធធារាសាស្ត្រ ក្នុងស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ដែលត្រូវលើកគំរោងជួសជុលឡើងវិញ





ទំនប់បង្ហៀរ ក្នុងប្រព័ន្ធធារាសាស្ត្រ កំពង់រទេះ ដែលមិនទាន់ជួសជុលឡើងវិញ ក្នុងស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង

ទំនប់បង្ហៀរក្នុងប្រព័ន្ធធារាសាស្ត្រ កំពង់រទេះ ក្រោយពេលជួសជុលរួចជាស្ថាពរ



ការចារស្តារ និងកសាងឡើងវិញទំនប់អាងទឹកឈ្វាំង ក្នុងស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង

ទំនប់អាងទឹកឈ្វាំងស្ថិតនៅក្នុងឃុំរលាប្អៀរ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ដែលមានខ្ពងលើប្រវែង ៥ ម៉ែត្រ កំពស់ ៣ ម៉ែត្រ បណ្តោយប្រវែង ៦៥០ ម៉ែត្រ និងសំណង់ទ្វារទឹក ០១ កន្លែង ។ មុនពេលសាសង់ទំនប់អាងទឹកឈ្វាំង មិនអាចរក្សាទឹកបានគ្រប់គ្រាន់ ដោយសារទំនប់មានការខូចខាត និងទ្រុឌទ្រោម ចំណែកសំណង់ទ្វារទឹកបានខូចខាតទាំងស្រុង ដែលជាហេតុបណ្តាលអោយប្រជាកសិករជួបនូវការខ្វះទឹកសំរាប់ការងារបង្កបង្កើនផល និងប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ។ ដោយមានការចង្អុលបង្ហាញ និងបញ្ជាផ្ទាល់ពីសំណាក់សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ក្រសួងធនធានទឹក និងឧតុនិយម បានចាប់ផ្តើមអនុវត្តការងារសាងសង់ទំនប់អាងទឹកឈ្វាំងនៅថ្ងៃទី ០៣ ខែមករា ឆ្នាំ ២០០៥ ។ ការស្តារ និងកសាងឡើងវិញទំនប់អាងទឹកឈ្វាំង និងអាចធ្វើអោយប្រជាកសិករចំនួន ០៤ ភូមិបស់ឃុំរលាប្អៀរមានប្រភពទឹកសំរាប់ប្រើប្រាស់ក្នុងការងារបង្កបង្កើនផលស្រូវនៅរដូវវស្សាបានចំនួន ៤០០ ហិកតា ដំណាំរួមផ្សំ ១០០ហិកតា និងសំរាប់ប្រើប្រាស់ក្នុងជីវភាពរស់នៅរដូវប្រាំង ។ ម្យ៉ាងវិញទៀតតួទំនប់អាងទឹកឈ្វាំងអាចធ្វើជាមធ្យោបាយសំរាប់ធ្វើដំណើរក្នុងមូលដ្ឋាន ព្រមទាំងដឹកកសិផលយកទៅលក់នៅទីផ្សារបានល្អប្រសើរថែមទៀត ។



ស្ថានភាពទំនប់ និងប្រឡាយអាងទឹកឈ្វាំង ក្រោយពេលសាងសង់រួច



ស្ថានភាពសំណង់ទ្វារទឹក ក្រោយពេលជួសជុល

ការងារជួសជុល ទំនប់អាងទឹកព្រែកតាកុយ ស្ថិតក្នុងស្រុកជលគីរី ខេត្តកំពង់ឆ្នាំង







សកម្មភាពកំពុងជួសជុលជើងទំនប់
អាងទឹកព្រែកតាកុយ



សកម្មភាព
កំពុងជួសជុល
ជំរាលទំនប់
អាងទឹក
ព្រែកតាកុយ





សកម្មភាពកំពុងជួសជុល និងរៀបចំថ្មធំការពារជំរាលទំនប់អាងទឹក ព្រែកតាកុយ



ទំនប់អាងទឹក ព្រែកតាកុយ ក្រោយពេលជួសជុល, រៀបចំថ្មភ្នំការពារជំរាល និងដាក់ដាំដើមត្រស់

ប្រព័ន្ធការពារទឹកប្រៃឆ្នាបាត់ ១+២ ស្ថិតនៅភូមិឆ្នាបាត់ ឃុំស្ទឹងវែង ស្រុកស្ទាច់មានជ័យ ខេត្តកោះកុង



សកម្មភាពកំពុងជួសជុលប្រព័ន្ធការពារទឹកប្រៃឆ្នាបាត់ ១ + ២ ស្ថិតនៅភូមិឆ្នាបាត់ ឃុំស្ទឹងវែង ស្រុកស្ទាច់មានជ័យ ខេត្តកោះកុង



ប្រព័ន្ធការពារទឹកប្រៃឆ្នាបាត់ ១ + ២ ក្រោយពេលជួសជុល ដែលអាចស្រោច ស្រពលើផ្ទៃដី ២០០,៧៨ ហិកតា បំរើ ដល់ការងារកសិករចំនួន ៤២៦ គ្រួសារ



ទិដ្ឋភាពទំនប់ការពារទឹកប្រៃស្រែថ្មី ស្ថិតនៅឃុំស្ទឹងវែង ស្រុកស្ទាច់មានជ័យ ខេត្តកោះកុង មុនពេលជួសជុល



ទំនប់ការពារទឹកប្រៃស្រែថ្មី ក្រោយពេលជួសជុល ដែលអាចស្រោចស្រព លើផ្ទៃដី ២២០ ហិកតា បំរើដល់ជីវភាពកសិករ ចំនួន ១៦៥ គ្រួសារ

ទំនប់ការពារទឹកប្រៃព្រែនប់ ស្ថិតក្នុងខណ្ឌព្រែនប់ ក្រុងព្រះសីហនុ









សកម្មភាពឯកឧត្តម លឹម គានហោ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ចូលរួមជាអធិបតីភាពក្នុងពិធីសម្ពោធ សំណង់ស្ងាក់ទឹកលើទំនប់ការពារទឹកប្រៃកំពង់ពត ស្ថិតក្នុងសង្កាត់រាម ខណ្ឌព្រែនប់ ក្រុងព្រះសីហនុ ដែលជាជំនួយឥតសំណងរបស់រាជរបស់រដ្ឋាភិបាលជប៉ុន



សកម្មភាពគ្រឿងចក្រជីកប្រឡាយ លើកទំនប់ការពារទឹកប្រៃព្រែនប់ ស្ថិតក្នុងខណ្ឌព្រែនប់ ក្រុងព្រះសីហនុ



ប្រឡាយ ទំនប់ការពារទឹកប្រៃព្រែនប់ ក្រោយពេលស្តារ និងសាងសង់រួច



តួទំនប់ការពារទឹកប្រៃព្រែនប់ មិនទាន់ជួសជុល



សកម្មភាពកំពុងជួសជុល តួទំនប់ការពារទឹកប្រៃព្រែនប់



តួទំនប់ការពារទឹកប្រៃព្រែនប់ ក្រោយពេលជួសជុល



ត្នូទំនប់ទំនប់ការពារទឹកប្រៃព្រៃនប់ ស្ថិតក្នុងឧឡើព្រៃនប់ ក្រុងព្រះសីហនុ



សំឡាងស្ទាក់ទឹកលើទំនប់ការពារទឹកប្រៃព្រៃនប់ ស្ថិតក្នុងឧឡើព្រៃនប់ ក្រុងព្រះសីហនុ



សម្តេច ហ៊ុន សែន នាយកដ្ឋមន្ត្រីនៃកាបដ្ឋាភិបាលកម្ពុជា អមដំណើរដោយឯកឧត្តម លីម គានហោ
ដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ចុះពិនិត្យការដ្ឋានអាងទឹកឈ្យាំង



ប្រពំន្ធធាកសាស្ត្រ ទប់ស្កាត់ទឹកបំនន់ និងក្រោះកំងស្ងួត



ទិសគីជាកត្តាចំបង ក្នុងការអភិវឌ្ឍន៍លើគ្រប់វិស័យ